**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃកិច្ចប្រជុំថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ដើម្បីដោះស្រាយវិវាទការងារនៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត

នារសៀលថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ នេះ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឯកឧត្តម ទេស រុក្ខាផល អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា បានបន្តជួបសម្របសម្រួលដោះស្រាយករណីវិវាទការងារនៅក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត ដោយមាន លោកស្រី ឈឹម ស៊ីថរ និង លោកមេធាវី ហម ស៊ុនរិទ្ធិ ជាតំណាងអតីតបងប្អូនកម្មករនិយោជិតទាំង ៣៥៧នាក់ ដែលមិនទាន់ឯកភាពក្នុងការទទួលយកការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ និង លោក Mike Ngai ជាតំណាងភាគីក្រុមហ៊ុន។ ជាលទ្ធផល ភាគីទាំងពីរនៅតែមិនទាន់ព្រមព្រៀងក្នុងការបញ្ចប់ករណីវិវាទនៅឡើយ ដោយភាគីអតីតបងប្អូនកម្មករនិយោជិតដែលនៅសេសសល់ពីការព្រមទទួលយកសំណងទូទាត់បញ្ចប់កិច្ចសន្យាតាមច្បាប់ នៅតែបន្តទាមទារឱ្យក្រុមហ៊ុនទទួលយកចូលធ្វើការវិញ ចំណែកឯភាគីក្រុមហ៊ុននៅតែរក្សាជំហរមិនទទួលយកចូលធ្វើការវិញទេ ដោយឯកភាពទូទាត់សំណងត្រឹមត្រូវតាមច្បាប់។

គិតត្រឹមថ្ងៃនេះ ក្រសួងបានខិតខំជួបសម្របសម្រួលដោះស្រាយជាមួយភាគីតំណាងអតីតបងប្អូនកម្មករនិយោជិត និងតំណាងភាគីក្រុមហ៊ុន បានចំនួន ៥លើក រួចហើយមក ក្រោយពេលមានការតវ៉ា កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ប៉ុន្តែនៅតែមិនទាន់ព្រមព្រៀងក្នុងការបញ្ចប់ករណីវិវាទនៅឡើយ។

យោងតាមច្បាប់ស្តីពីការងារ នីតិវិធីដោះស្រាយវិវាទការងាររួមបែបនេះ ត្រូវឆ្លងកាត់ការផ្សះផ្សាដោយអធិការការងារ ហើយក្នុងករណីមិនសះជា វិវាទនឹងត្រូវបញ្ជូនទៅដោះស្រាយដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ប្រសិនបើមានភាគីបដិសេធមិនអនុវត្តសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល សាមីភាគីអាចប្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីស្នើសុំឱ្យអនុវត្តសេចក្តីបង្គាប់នោះ។ ក្នុងករណី ភាគីវិវាទស្នើសុំធ្វើកូដកម្ម ត្រូវអនុវត្តតាមនីតិវិធី និងសេចក្តីសម្រេចរបស់តុលាការ។

ដើម្បីចូលរួមថែរក្សាផលប្រយោជន៍ស្របច្បាប់របស់អតីតបងប្អូនកម្មករនិយោជិត និងក្រុមហ៊ុនដែលកំពុងមានវិវាទ ក្រសួងនឹងបន្តព្យាយាមធ្វើការសម្របសម្រួលដោះស្រាយករណីនេះទៅតាមនីតិវិធីត្រឹមត្រូវនៃច្បាប់ជាមួយអតីតបងប្អូនកម្មករនិយោជិត និងក្រុមហ៊ុន នៅទីស្តីការក្រសួងជាបន្តទៀត។

ក្រសួងបន្តអំពាវនាវឱ្យអតីតបងប្អូនកម្មករនិយោជិត ក៏ដូចជានិយោជកចូលរួមសហការជាមួយក្រសួង និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបញ្ចប់ករណីវិវាទនេះ ចៀសវាងឱ្យបានដាច់ខាតពីការប្រព្រឹត្តិសកម្មភាពណាមួយដែលនាំឱ្យខូចខាតដល់ប្រយោជន៍របស់ភាគីទាំងពីរ ព្រមទាំងឈានទៅទទួលរងនូវផលវិបាកតាមផ្លូវច្បាប់ជាយថាហេតុ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបងប្អូនកម្មករនិយោជិត និយោជក និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

*ថ្ងៃចន្ទ ៨រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៥*